ការពន្លឿនការអនុម័តបទប្បញ្ញត្តិស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

ការពន្លឿនការអនុវត្តបទប្បញ្ញត្តិស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក នៅប្រទេសកម្ពុជា និង មីយ៉ាន់ម៉ា។

# ការលក់ សេវាកម្មដឹកជញ្ជូន និងធ្វើដំណើរ តាមអនឡាញ នៅប្រទេសកម្ពុជា

GOOD PRACTICE GUIDE CAMBODIA

tradeWorthy

Australian Aid

# បុព្វកថា



ឯកឧត្តម ប៉ាន សូរស័ក្តិ
រដ្ឋមន្ត្រី
ក្រសួងពាណិជ្ជកម្ម
រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងពាណិជ្ជកម្មមានសេចក្តីសោមនស្សរីករាយក្នុងការរួមកម្លាំងគ្នាជួយដល់សហគ្រាសខ្នាតមីក្រូតូច និងមធ្យម (Micro, Small and Medium Enterprises,MSME)ឱ្យមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សទៅរកការផ្តល់ទំនិញ និងសេវាកម្មពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចដែលជាការឆ្លើយតបទៅនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។ ការពន្លឿនល្បឿនក្នុងការអនុម័តលើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចដោយពាណិជ្ជករ និងអ្នកប្រើប្រាស់នៅក្នុងប្រទេសកម្ពុជាផ្តល់នូវអត្ថប្រយោជន៍ជាច្រើន ដូចជា ការកើនឡើងនៃការធ្វើឱ្យអាជីវកម្មមានលក្ខណៈផ្លូវការ ការរួមបញ្ចូលហិរញ្ញវត្ថុឌីជីថលល្អប្រសើរ និងការធ្វើឱ្យអាជីវកម្មមានលក្ខណៈឌីជីថល។ វាក៏នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការស្តារសេដ្ឋកិច្ចរបស់យើង និងការរីកចម្រើនទៅថ្ងៃអនាគតផងដែរ។ គោលការណ៍ណែនាំសម្រាប់ការអនុវត្តល្អ (GPG) ទាំងបួននឹងជួយ MSME នៅលើវិស័យអាទិភាពក្នុងការរៀបចំផែនការ និងអនុវត្តការផ្លាស់ប្តូរទៅរកការផ្តល់ទំនិញ និងសេវាកម្មដោយប្រើវិធីសាស្រ្តពាណិជ្ជតាមប្រព័ន្ធអេឡិចត្រូនិច ស្របតាមបទប្បញ្ញត្តិរបស់រដ្ឋាភិបាល និងការអនុវត្តឧស្សាហកម្មល្អៗ។ GPG ទាំងនេះទទួលបានអត្ថប្រយោជន៍ពីឧស្សាហកម្មឈានមុខគេ នៅក្នុងប្រទេសកម្ពុជា។ ទាំងនេះគឺជាឧបករណ៍សំខាន់មួយនៃការប្តេជ្ញាចិត្តដ៏មុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្លាស់ប្តូរទៅរកសេដ្ឋកិច្ចឌីជីថល។ យើងសូមថ្លែងអំណរគុណចំពោះរដ្ឋាភិបាលអូស្ត្រាលីដែលបានផ្តល់ការគាំទ្រ ដើម្បីពន្លឿនការអនុម័តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចនៅកម្ពុជា។

គំនិតផ្តួចផ្តើមជំនួយអូស្ត្រាលីដែលផ្តល់មូលនិធិតាមរយៈការិយាល័យចរចាផ្នែកពាណិជ្ជកម្មរបស់អូស្ត្រាលី និងផ្តល់ដោយ Tradeworthy ជាផ្នែកមួយនៃជំនួយពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិចសម្រាប់មូលនិធិពាណិជ្ជកម្ម។

# នេះជាពេលវេលាដែលត្រូវជួយ ‘ផ្លាស់ប្តូរ’ កម្ពុជា ឱ្យធ្វើអាជីវកម្មតាមអនឡាញហើយ!

## វីរុសកូវីដ-១៩ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់របៀបទិញលក់ផលិតផល និងសេវាកម្មរបស់យើង។

ទន្ទឹមនឹងបញ្ហាប្រឈមផ្សេងៗ វីរុសនេះក៏បង្កើតឱ្យមានឱកាសថ្មីៗសម្រាប់អ្នកបើកបរ និងអ្នកដឹកជញ្ជូនផងដែរ។ ការផ្ទេរទំនិញគឺជាឱកាសដ៏មានសារៈសំខាន់មួយ។ ស្របតាមពិភពលោកទាំងមូលដែរ ប្រជាជនកម្ពុជាបានប្តូរមកទិញទំនិញចាំបាច់ជាមូលដ្ឋានដែលរាប់តាំងពីអាហារក្តៅៗ គ្រឿងទេស រហូតដល់ទឹកលាងដៃសម្លាប់មេរោគ និងម៉ាស់តាមអនឡាញ។

ផលិតផលទាំងអស់នេះត្រូវដឹកជញ្ជូនទៅឱ្យអ្នកប្រើប្រាស់ឱ្យបានឆាប់រហ័ស និងប្រកបដោយសុវត្ថិភាព។ តម្រូវការដឹកជញ្ជូនទំនិញពីកន្លែងមួយទៅកន្លែងមួយទៀតកំពុងកើនឡើងយ៉ាងឆាប់រហ័ស ស្របតាមកំណើននៃការប្រើប្រាស់ទូរសព្ទឆ្លាតវៃ និងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក។ ជាក់ស្តែង មនុស្ស ១០០ នាក់នៅកម្ពុជាជាវទូរសព្ទឆ្លាតវៃ ១២៨ គ្រឿង!

ដោយសារវីរុសនេះបានធ្វើឱ្យមនុស្សទិញសម្ភារប្រើប្រាស់ និងបរិក្ខារក្នុងផ្ទះតាមអនឡាញប្រកបដោយភាពងាយស្រួលខ្លាំងជាងមុន ការទិញតាមអនឡាញទំនងជានឹងបន្តកើនឡើងទៀត ទោះបីជានៅក្រោយពេលដែលវីរុសនេះរលាយសូន្យក៏ដោយ។

បម្លាស់ទីរបស់ប្រជាជនក្នុងទីក្រុង និងពីទីក្រុងមួយទៅទីក្រុងមួយទៀត គឺជាឱកាសមួយផ្នែកទៀត។ អ៊ីនធឺណិតក៏កំពុងដើរតួជាអ្នកដឹកនាំការរីវឌ្ឍក្នុងវិស័យដឹកជញ្ជូនផងដែរ ដោយធ្វើឱ្យកាន់តែមានសុវត្ថិភាព កាន់តែមានអនាម័យ និងកាន់តែមានប្រសិទ្ធភាព។ ប្រព័ន្ធអនឡាញដែលកំពុងរីកដុះដាលត្រូវការអ្នកបើកបរដែលមានបទពិសោធន៍ឥតឈប់ឈរ ដើម្បីដឹកជញ្ជូនអ្នកដំណើរ (និងផលិតផល) ពីកន្លែងមួយទៅកន្លែងមួយទៀត។

ដូច្នេះ គ្មានពេលវេលាណាប្រសើរជាងពេលនេះទៀតឡើយ ក្នុងការចាប់ឱកាស‘ផ្លាស់ប្តូរ’ មកធ្វើអាជីវកម្មតាមអនឡាញ។ ឯកសារណែនាំអំពីការអនុវត្តដ៏ប្រសើរនេះ នឹងដាក់ចេញនូវជម្រើសសំខាន់ៗ សម្រាប់ឱ្យអ្នកធ្វើការពិចារណាអំពីរបៀបដាក់អាជីវកម្មរបស់អ្នកឱ្យមានវត្តមានតាមអនឡាញព្រមជាមួយគន្លឹះជាក់ស្តែងជាច្រើន ដើម្បីជួយឱ្យអ្នកទទួលបានភាពជោគជ័យ។

### ករណីសិក្សា

**រ៉ាមែនចូលរួមជាមួយកម្មវិធីកក់ការធ្វើដំណើរមួយ**

រ៉ាមែនបានធ្វើការនៅក្នុងវិស័យបដិសណ្ឋារកិច្ចក្នុងទីក្រុងភ្នំពេញអស់រយៈពេលជាងមួយទសវត្សរ៍ហើយ។ គាត់បានធ្វើជាអ្នកទទួលភ្ញៀវនៅសណ្ឋាគារបូទិកដ៏ល្បីឈ្មោះមួយកន្លែង។ ធ្វើការនៅទីនោះអស់រយៈពេលជាច្រើនឆ្នាំ ប្រាក់ខែរបស់គាត់បានកើនឡើងគួរឱ្យកត់សម្គាល់ដែលអាចឱ្យគាត់មានលទ្ធភាពទិញផ្ទះ និងរថយន្តបាន។ រ៉ាមែនចូលចិត្តជួបជាមួយអតិថិជនថ្មីៗពីជុំវិញពិភពលោក និងផ្តល់ដំបូន្មានក៏ដូចជាការយល់ដឹងស៊ីជម្រៅដល់ពួកគេអំពីអ្វីដែលគួរធ្វើ និងគួរទស្សនានៅទីក្រុងភ្នំពេញ និងទូទាំងប្រទេសកម្ពុជា ខណៈដែលគាត់មានមោទនភាពខ្លាំងចំពោះកេរដំណែលពីដូនតារបស់គាត់។

រ៉ាមែនក៏ជាបុរសមានគ្រួសារ និងជាស្វាមីដែលមានសុភមង្គលរបស់សុភ័ក្ត្រព្រមទាំងជាឪពុកដែលមានមោទនភាពរបស់កូនស្រីតូចៗបីនាក់ផងដែរ។ បទពិសោធន៍របស់គាត់ក្នុងវិស័យបដិសណ្ឋារកិច្ចបានបង្រៀនគាត់អំពីសារៈសំខាន់នៃការសិក្សាភាសាផ្សេងទៀត ដូច្នេះគាត់បានធ្វើឱ្យប្រាកដថា គាត់បានដាក់ទុនលើការអប់រំរបស់កូនស្រី និងឱ្យកូនៗរៀនភាសាអង់គ្លេសនិងចិន នៅសាលារៀន ដើម្បីឱ្យពួកគេមានអនាគតភ្លឺស្វាង។

ដោយសារតែស្ថានភាពវីរុសកូរ៉ូណា វិស័យទេសចរណ៍បានដួលរលំ ហើយរ៉ាមែនបានបាត់បង់ការងារដោយសារសណ្ឋាគារដែលគាត់ធ្វើការបានបិទ។

ប្អូនប្រុសរបស់គាត់បានណែនាំថា គាត់អាចប្រើរថយន្តរបស់គាត់ដើម្បីរកប្រាក់ចំណូល ខណៈពេលដែលវិបត្តិផ្នែកបដិសណ្ឋារកិច្ចនៅតែបន្ត។ ដោយចេះភាសាអង់គ្លេសច្រើនគួរសម និងយល់ដឹងស៊ីជម្រៅអំពីទីក្រុង យោបល់នេះហាក់ដូចជាជម្រើសដ៏ស័ក្តិសមបំផុត ទម្រាំគាត់អាចត្រឡប់ទៅធ្វើការនៅសណ្ឋាគារវិញ។ ដោយមានជំនួយពីប្អូនប្រុស គាត់បានរៀបចំព័ត៌មានចាំបាច់ទាំងអស់ ដើម្បីចុះឈ្មោះប្រើកម្មវិធីកក់ការធ្វើដំណើរ ហើយបានដាក់ពាក្យសុំធ្វើជាអ្នកបើកបរតាក់ស៊ីបានដោយជោគជ័យ។

# របៀបរៀបចំគម្រោងដើម្បីប្តូរ ទៅជាការលក់តាមអនឡាញ

ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩បានជះឥទ្ធិពលយ៉ាងខ្លាំងដល់វិស័យធ្វើដំណើរ និងទេសចរណ៍ ដោយធ្វើឱ្យប្រាក់ចំណូលរបស់អ្នកបើកបរកង់បីឥណ្ឌា កង់បីខ្មែរ រថយន្តធុនតូច និងយានជំនិះជាច្រើនផ្សេងទៀតធ្លាក់ចុះ។ ប្រសិនបើអ្នកជាអ្នកបើកបរដែលមានបទពិសោធន៍មានយានជំនិះដែលបានចុះបញ្ជី និងមានស្មារតីជាសហគ្រិននោះការស្វែងរកប្រភពចំណូលថ្មីៗគឺជារឿងដែលគួរធ្វើ។

ប្រភេទអាជីវកម្មតាមអ៊ីនធឺណិតដែលមានការពេញនិយមខ្លាំងឡើងៗ ដែលភ្ជាប់ទំនាកទំនងជាមួយអ្នកបើកបរគឺកម្មវិធី 'កក់ការធ្វើដំណើរ' ដោយអ្នកដំណើរត្រូវបានផ្គូផ្គងជាមួយអ្នកបើកបរ ដើម្បីធ្វើដំណើរ ដែលជាធម្មតាធ្វើឡើងនៅក្នុងទីក្រុង។ បច្ចុប្បន្ន អាជីវកម្មទាំងនេះកំពុងបែកមែកសាខាទៅក្នុងវិស័យផ្សេងទៀតដូចជា ការដឹកជញ្ជូនគ្រឿងទេស និងចំណីអាហារជាដើម។ ទន្ទឹមនឹងនេះ ក៏មានក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកដែលផ្តោតទាំងស្រុងលើការលក់ និងការដឹកជញ្ជូនអាហារ គ្រឿងទេស ទំនិញប្រើប្រាស់ក្នុងផ្ទះ និងផលិតផលផ្សេងទៀតតាមអនឡាញផងដែរ។ អាជីវកម្មទាំងនេះជាច្រើនពឹងផ្អែកលើបណ្តាញអ្នកដឹកជញ្ជូននានា។ ការចូលរួមជាមួយ 'ប្រព័ន្ធដឹកជញ្ជូន' ទាំងនេះអាចជាឱកាសពិសេសក្នុងការទទួលបានប្រាក់ចំណូលបន្ថែម។



ករណីសិក្សា

**ស្រីកានាំមកនូវគ្រឿងទេស!**

ស្រីកាគឺជាអ្នកបើកបរឱ្យក្រុមហ៊ុនទេសចរណ៍មួយនៅខេត្តសៀមរាប ដោយនាំក្រុមទេសចរណ៍នារីទៅលេងប្រាសាទ។ កាលពីបីឆ្នាំមុន គ្រួសាររបស់គាត់បានទិញរថយន្តដឹកភ្ញៀវខ្នាតតូចផ្ទាល់ខ្លួនមួយគ្រឿងដែលអាចឱ្យស្រីកាបង្កើនប្រាក់ចំណូលផង និងនៅតែធានាថាកូនៗរបស់គាត់បានទៅដល់សាលារៀនដោយសុវត្ថិភាពជារៀងរាល់ថ្ងៃផង។

ដោយសារតែស្ថានភាពវីរុសកូរ៉ូណា ចំនួនភ្ញៀវទេសចរណ៍បរទេសមានការធ្លាក់ចុះយ៉ាងគំហុក។ ក្រុមហ៊ុនទេសចរណ៍របស់គាត់លែងត្រូវការគាត់ឱ្យធ្វើការទៀតហើយ។

ចាន់ថនដែលជាស្វាមីរបស់គាត់ធ្វើការនៅហាងលក់បន្លែផ្លែឈើមួយកន្លែង ហើយបានផ្តល់ដំបូន្មានឱ្យគាត់ចុះឈ្មោះចូលរួមជាមួយក្រុមហ៊ុនដឹកជញ្ជូនគ្រឿងទេសក្នុងតំបន់ដែលលក់ឱ្យសាលារៀន និងក្រុមហ៊ុននានានៅក្នុងតំបន់ជាចម្បង។ ដោយមានជំនួយពីស្វាមី គាត់បានប្រមូលព័ត៌មានចាំបាច់ទាំងអស់ ដើម្បីចាប់ផ្តើម។

# របៀបជ្រើសរើស និងចូលរួមជាមួយ
# ប្រព័ន្ធធ្វើដំណើរ/ដឹកជញ្ជូន

### ប្រសិនបើអ្នកចង់ចូលរួមជាមួយប្រព័ន្ធធ្វើដំណើរ ឬប្រព័ន្ធដឹកជញ្ជូនតាមអនឡាញ អ្នកអាចប្រៀបធៀបជម្រើសផ្សេងៗដោយផ្តោតលើសំណួរសំខាន់ៗទាំងនេះ៖

- តើប្រព័ន្ធដឹកជញ្ជូនណាខ្លះដែលអាចចូលរួមបាននៅក្នុងតំបន់របស់ខ្ញុំ?
- តើប្រភេទយានជំនិះ និងបទពិសោធន៍ដូចម្តេចខ្លះដែលប្រព័ន្ធនោះត្រូវការពីអ្នកបើកបរ?
- តើចំណាយសម្រាប់ការរៀបចំជាមួយប្រព័ន្ធនីមួយៗមានតម្លៃប៉ុន្មាន?
- តើប្រព័ន្ធនោះអាចជួយឱ្យខ្ញុំប្រកបរបរតាមអនឡាញដោយមានប្រសិទ្ធភាពកម្រិតណា? តើប្រព័ន្ធណាទៀតអាចជួយខ្ញុំបាន?
- តើមានលក្ខខណ្ឌទូទាត់ប្រាក់ដូចម្តេចខ្លះ?
- តើពួកគេទូទាត់ប្រាក់តាមរបៀបណា និងល្បឿនកម្រិតណា?

គួរអោយចងចាំផងដែរថា --- ពាណិជ្ជកម្មនេះគឺត្រូវការអ្នកបើកបរដែលទទួលបានវគ្គបណ្តុះបណ្តាល មានវិន័យ និងមានឆន្ទៈក្នុងការរៀនពីដំណើរការថ្មីដែលពាក់ពន្ធទៅនឹងបច្ចេកវិទ្យា និងអតិថិជន។ វានឹងត្រូវការប្តេជ្ញាពិតប្រាកដ។

## ការចុះឈ្មោះប្រើប្រព័ន្ធធ្វើដំណើរ និងដឹកជញ្ជូនតាមអនឡាញ

សំណាងល្អ ដំណើរការចុះឈ្មោះធ្វើជាដៃគូដឹកជញ្ជូនក្នុងកម្មវិធីកក់ការធ្វើដំណើរ/ដឹកជញ្ជូនទាំងអស់មានលក្ខណៈស្រដៀងគ្នាច្រើន ដោយតម្រូវឱ្យមានព័ត៌មានដូចៗគ្នាអំពីអ្នក និងយានជំនិះរបស់អ្នក ដើម្បីបង្កើតកម្រងព័ត៌មានដៃគូពេញលេញ។



## *ជាធម្មតា ការដំណើរការជាមូលដ្ឋានមានដូចខាងក្រោមៈ*

### ជំហានទី១

ដំឡើងកម្មវិធីដៃគូនៅលើទូរសព្ទឆ្លាតវៃរបស់អ្នក។ ជាញឹកញាប់ មានកម្មវិធី 'អ្នកបើកបរ' ដាច់ដោយឡែក ឬតំណភ្ជាប់នៅក្នុងកម្មវិធីអតិថិជនសម្រាប់ទាក់ទងទៅក្រុមហ៊ុន ដើម្បីចូលរួមជាដៃគូដឹកជញ្ជូន។ ក្នុងករណីមួយចំនួន អ្នកនឹងត្រូវដាក់បញ្ជូនឯកសារសំខាន់ៗតាមរយៈប្រព័ន្ធអនឡាញ មុននឹងដំឡើងកម្មវិធី។

### ជំហានទី២

អ្នកនឹងត្រូវផ្តល់ព័ត៌មានបឋមដូចខាងក្រោម ដោយអាស្រ័យលើលក្ខខណ្ឌតម្រូវរបស់ប្រព័ន្ធកក់ការធ្វើដំណើរ/ដឹកជញ្ជូនរបស់អ្នក

- ឈ្មោះ
- រូបថត (ថតរូបសែលហ្វីដោយប្រើទូរសព្ទរបស់អ្នក)
- លេខទូរសព្ទ
- អ៊ីមែល (មិនតម្រូវ)
- លេខបណ្ណបើកបរ
- ប្រភេទយានជំនិះ (កង់បីឥណ្ឌា កង់បីខ្មែរ រថយន្តធុនតូច រថយន្តដឹកភ្ញៀវខ្នាតតូច រថយន្តប្រភេទ SUV)
- ម៉ូដែល / ពណ៌ / ឆ្នាំផលិត / រូបថតយានជំនិះ
- ស្លាកលេខយានជំនិះ / លេខសម្គាល់យានជំនិះ
- ចំនួនកៅអីអ្នកដំណើរ
- រូបថតបណ្ណបើកបរ (មុខនិងក្រោយ)
- ព័ត៌មានពិសេស (ម៉ាស៊ីនត្រជាក់ សត្វចិញ្ចឹមដែលអនុញ្ញាត បុគ្គលមានពិការភាព កន្លែងដាក់អីវ៉ាន់បន្ថែម ការអនុញ្ញាតឱ្យជក់បារី កៅអីកុមារ។ល។)

### ជំហានទី៣

ទទួល ពិនិត្យមើល និងទទួលយកកិច្ចសន្យាស្តីពីកម្រិតសេវាកម្មដែលផ្តល់ជូន។ យកចិត្តទុកដាក់ខ្លាំងចំពោះ៖

- ថ្លៃសេវាចុះឈ្មោះ (ក្រុមហ៊ុនកក់ការធ្វើដំណើរមិនគិតថ្លៃសេវាចុះឈ្មោះទេ។ ប៉ុន្តែក្រុមហ៊ុនភាគច្រើនតម្រូវឱ្យអ្នកបើកបរតម្កល់សមតុល្យខ្លះក្នុងកាបូបលុយនៃកម្មវិធីអ្នកបើកបររបស់ពួកគេ ទើបអាចបើកបរបាន)។
- អត្រាកម្រៃជើងសារ (ឬហៅថាអត្រាដកភាគរយ) និងអត្រាកក់ថេរ។
- លក្ខខណ្ឌ និងវិធីទូទាត់ប្រាក់
- លក្ខខណ្ឌសម្រាប់ការលុបចោលការធ្វើដំណើរ
- លក្ខខណ្ឌសម្រាប់ការលុបចោលកិច្ចសន្យា
- រចនាសម្ព័ន្ធនៃចំណូលសុទ្ធសម្រាប់ពេលថ្ងៃ និងពេលយប់ (លើកដៃហៅ ចំណាយអប្បបរមាក្នុងមួយគីឡូម៉ែត្រក្នុងមួយនាទី)
- លក្ខខណ្ឌតម្រូវស្តង់ដារសម្រាប់សេវាកម្ម ដែលនឹងខុសគ្នាគួរឱ្យកត់សម្គាល់រវាងប្រព័ន្ធនានាដោយអាស្រ័យលើប្រភេទធ្វើដំណើរ ឬដឹកជញ្ជូនដែលអ្នកកំពុងផ្តល់ជូន
- ការត្រួតពិនិត្យសុវត្ថិភាព និងអនុលោមភាព ដើម្បីធានាថាអ្នក និងយានជំនិះរបស់អ្នកគឺជាអ្នកផ្តល់សេវាកម្មធ្វើដំណើរដែលមានសុវត្ថិភាព
- លក្ខខណ្ឌតម្រូវសម្រាប់ក្រុមហ៊ុនធានារ៉ាប់រង



## ជំហានទី៤

(សម្រាប់ការកក់ការធ្វើដំណើរតែប៉ុណ្ណោះ) ពិនិត្យមើលកម្រងព័ត៌មានតាមអនឡាញរបស់អ្នកដែលផ្សាយដោយប្រព័ន្ធកក់ការធ្វើដំណើរនោះ។ ត្រូវប្រាកដថាព័ត៌មានលម្អិតទាំងអស់មានភាពត្រឹមត្រូវ។

## ជំហានទី៥

ស្នើសុំការបណ្តុះបណ្តាលដោយផ្ទាល់ ឬតាមទូរសព្ទ ប្រសិនបើត្រូវការ។ ក្នុងករណីមួយចំនួន ខ្លឹមសារបណ្តុះបណ្តាល (រួមទាំងតំណភ្ជាប់ទៅវីដេអូ) នឹងផ្ញើទៅអ្នក បន្ទាប់ពីបានបញ្ជាក់ថាអ្នកជាអ្នកបើកបររួច។

## ជំហានទី៦

ចាប់ផ្តើមធ្វើការដើម្បីបង្កើនប្រាក់ចំណូលរបស់អ្នក!

## ករណីសិក្សា

**រ៉ាំមែនចាប់ផ្តើមមមាញឹកក្នុងមួយប៉ប្រិចភ្នែក!**

រ៉ាំមែនបានចុះឈ្មោះប្រើកម្មវិធីកក់ការធ្វើដំណើរតាមទូរសព្ទចល័តចំនួនពីរក្នុងរយៈពេលតិចជាងមួយសប្តាហ៍។ បន្ទាប់ពីបញ្ចប់ការត្រួតពិនិត្យសុវត្ថិភាពរួចរាល់ គាត់យល់ថាថ្ងៃដឹកជញ្ជូនទីមួយរបស់គាត់ជុំវិញទីក្រុងភ្នំពេញមានភាពមមាញឹកខ្លាំង។ គាត់ទទួលការជូនដំណឹងអំពីការកក់នៅលើទូរសព្ទឆ្លាតវៃរបស់គាត់ដែលមានបញ្ជាក់ព័ត៌មានលម្អិតអំពីទីតាំងទៅទទួល/ទីតាំងគោលដៅ និងផ្លូវដែលត្រូវធ្វើដំណើរ។ ឥឡូវនេះ អាជីវកម្មកក់ការធ្វើដំណើរជួយគាត់ក្នុងការបង្កើនប្រាក់ចំណូលប្រចាំថ្ងៃដោយប្រើរថយន្តរបស់គាត់។

ដោយយល់ថាអតិថិជនមានអារម្មណ៍ថា ការកក់អ្នកបើកតាក់ស៊ីតាមទូរសព្ទមានភាពងាយស្រួលជាង ឥឡូវនេះ គាត់មានគម្រោងចុះឈ្មោះប្រើកម្មវិធីកក់ការធ្វើដំណើរច្រើនទៀត ដើម្បីបង្កើនឱកាសទទួលបានការកក់ និងប្រាក់ចំណូល។ គាត់រីករាយនឹងការហាត់និយាយភាសាអង់គ្លេស នៅពេលអ្នកដំណើរបរទេសឡើងជិះរថយន្ត។



# ការធ្វើការដោយប្រើកម្មវិធីធ្វើដំណើរ និងដឹកជញ្ជូន

**ជាទូទៅ កម្មវិធីធ្វើដំណើរ និងដឹកជញ្ជូន ដំណើរការដោយចាត់ចែងការងារឱ្យអ្នក បើកបរដែលទំនេរនៅទីតាំងជាក់លាក់។**

រាល់ការចាត់ចែងការងារទាំងអស់ធ្វើឡើងតាមរយៈ កម្មវិធីទូរសព្ទឆ្លាតវៃ ដូច្នេះអ្នកនឹងត្រូវស្គាល់មុខ ងារនានារបស់កម្មវិធីនោះ។ មុខងារទាំងនោះត្រូវ បានបង្កើតឡើងដោយមានភាពងាយស្រួលប្រើ ប្រាស់ខ្លាំង។ មុខងារសំខាន់ៗរួមមានៈ



### មុខងារពេលមាន/គ្មានអ៊ីនធឺណិត

មុខងារនេះជួយអ្នកក្នុងការគ្រប់គ្រងភាពទំនេររបស់អ្នកនៅលើកម្មវិធីនេះ។ ប្រសិនបើអ្នក កំពុងរង់ចាំទទួលការងារ អ្នកគ្រាន់តែរក្សាស្ថានភាពមានអ៊ីនធឺណិត និងនៅទំនេរជាការ ស្រេច។

### ទទួលយក/បដិសេធការកក់

នៅពេលមានការកក់ កម្មវិធីនោះនឹងតម្រូវឱ្យអ្នកទទួលយកការកក់នោះ ដើម្បីចាប់ផ្ដើម និងទទួលបានព័ត៌មានអំពីការកក់។ អ្នកនឹងត្រូវរហ័សរហួន ដើម្បីទទួលបានការងារល្អ បំផុត!

### ការបញ្ជាក់ការកក់

បន្ទាប់ពីអ្នកទទួលយកការកក់រួច អ្នកនឹងទទួលបានព័ត៌មានដូចជាៈ

- o ទីតាំងទៅទទួលអតិថិជនរបស់អ្នក
- o ទីតាំងគោលដៅរបស់អតិថិជន (ទោះមិនតម្រូវជាកំហិតក៏ដោយ)
- o វិធីទូទាត់ប្រាក់ (ឧ. សាច់ប្រាក់ ឬបណ្ណធនាគារ)
- o តម្លៃធ្វើដំណើរ
- o រយៈពេលធ្វើដំណើរ

### ផ្លូវដែលត្រូវធ្វើដំណើរ

ការធ្វើបែបនេះអាចបង្ហាញផ្លូវទៅកាន់គោលដៅដែលមានចម្ងាយជិតបំផុត ដើម្បីកុំឱ្យអ្នក វង្វេងផ្លូវ និងប្រាកដថាអ្នកមិនប្រើប្រេងសាំង/ហ្គាសច្រើនជ្រុលសម្រាប់ការងារនោះ។ អតិថិជនរបស់អ្នកក៏អាចមើលឃើញផ្លូវដែលបានណែនាំនៅលើកម្មវិធីរបស់គាត់ផងដែរ។

### ការកក់តាមកាលវិភាគ

អាចឱ្យអ្នកទទួលបានការកក់ជាមុនដែលនឹងជួយឱ្យអ្នកអាចព្យាករប្រាក់ចំណូលក្នុងមួយ សប្ដាហ៍ឬមួយខែ។ ទោះជាមុខងារនេះមាននៅក្នុងកម្មវិធីភាគច្រើនក៏ពិតមែន ប៉ុន្តែអ្នក ដំណើរកម្រប្រើវាណាស់។ ជាមួយគ្នានេះដែរ អ្នកក៏អាចពិចារណាចូលរួមក្រុមចែករំលែក តាក់ស៊ីតាម Facebook ដែលបង្ហាញការកក់ដែលមិនគិតកម្រៃជើងសារ។

### ផែនទីពណ៌

មុខងារឆ្លាតវៃដែលបង្ហាញអ្នកនូវទីតាំងដែលមានតម្រូវការអតិថិជនច្រើនបំផុត។ ព័ត៌មាន នេះមាន 'ផ្សាយផ្ទាល់' ដូច្នេះអ្នកអាចធ្វើដំណើរ និងកក់ការងារបានច្រើនបំផុត។

### ប្រវត្តិប្រតិបត្តិការ និងការកក់

ចូលមើលប្រវត្តិនៃការកក់របស់អ្នក ដើម្បីជួយអ្នកក្នុងការគណនាប្រាក់ចំណូលសរុបប្រចាំ ថ្ងៃឬខែដោយប្រើកម្មវិធីនោះ។ កម្មវិធីគួរតែបង្ហាញចំនួនទឹកប្រាក់ដែលប្រព័ន្ធនោះជំពាក់ អ្នកសម្រាប់ការងារដែលបានបំពេញផងដែរ។



## សុវត្ថិភាព សន្តិសុខ និងភាពអាចជឿទុកចិត្តបានគឺជាគន្លឹះឆ្ពោះទៅរកភាពជោគជ័យ

នៅក្នុងអាជីវកម្មធ្វើដំណើរ សុវត្ថិភាព សន្តិសុខ និងភាពអាចជឿទុកចិត្តបានគឺជាគន្លឹះដើម្បីផ្គាប់ចិត្តអតិថិជន។ អ្នកបើកបរដែលមិនគោរពតាមស្តង់ដារវិជ្ជាជីវៈផ្នែកបើកបរ និងសេវាបម្រើអតិថិជននឹងមិនអាចមានវត្តមានយូរនៅលើប្រព័ន្ធទាំងនោះទេ។ ប្រព័ន្ធទាំងនោះអាចដកពួកគេចេញដោយសារការបំពានកម្រិតសេវាកម្ម ហើយអតិថិជនអាចរាយការណ៍តាមរយៈការវាយតម្លៃ និង 'ការសម្គាល់' ថាជាការបើកបរ គ្មានសុវត្ថិភាព ឬជាការព្រួយបារម្ភផ្នែកសន្តិសុខ។

បន្ថែមលើការគោរពច្បាប់ចរាចរណ៍ ស្តង់ដារវិជ្ជាជីវៈមូលដ្ឋានមួយចំនួននឹងតម្រូវឱ្យមាន៖



- គោរពល្បឿនកំណត់ និងស្លាកសញ្ញាចរាចរណ៍
- រក្សាគម្លាតសមល្មមរវាងយានជំនិះ
- ត្រូវប្រាកដថាខ្សែក្រវ៉ាត់ការពាររបស់អ្នកដំណើរការជាប្រក្រតី
- គួរតែសម្រាកសិន មុននឹងមានអារម្មណ៍ថានឿយហត់ (យ៉ាងហោចណាស់រៀងរាល់ ២ ម៉ោងម្តង)
- កុំប្រើទូរសព្ទចល័តរបស់អ្នកខណៈពេលកំពុងបើកបរ ដោយប្រព័ន្ធទាំងនោះណែនាំឱ្យប្រើ 'ជើងទម្រ' ទូរសព្ទ ដែលនឹងអនុលោមតាមច្បាប់ចរាចរណ៍
- កុំពិសាគ្រឿងស្រវឹង
- ពិនិត្យភ្នែករបស់អ្នកជាទៀងទាត់ (សូមណែនាំឱ្យពិនិត្យរៀងរាល់បីខែម្តង)។
- កុំលេបថ្នាំដែលអាចប៉ះពាល់ដល់សមត្ថភាពបើកបររបស់អ្នក។
- ថែទាំយានជំនិះរបស់អ្នកជាទៀងទាត់ ដើម្បីបញ្ចៀសគ្រោះថ្នាក់ (កង់ សម្បកកង់ ហ្វ្រាំង ប្រេង។ល។)
- រក្សាសណ្តាប់ធ្នាប់យានជំនិះរបស់អ្នក

**គន្លឹះពីអ្នកជំនាញ៖** ក្នុងនាមជាអ្នកបើកបរយានជំនិះ អ្នកនឹងចំណាយពេលភាគច្រើននៅលើផ្លូវថ្នល់។ គួរពិចារណារកប្រាក់បន្ថែម ដោយដាក់ 'ផ្ទាំងផ្សព្វផ្សាយចល័ត' លើយានជំនិះរបស់អ្នក ដើម្បីផ្សាយពាណិជ្ជកម្មឱ្យអាជីវកម្មនានា។ អ្នកអាចជម្រាបអាជីវកម្មនានាអំពីសេវាកម្មនេះនៅលើទំព័រ Facebook របស់អ្នក ឬនៅពេលអ្នកដឹកជញ្ជូនទំនិញ ឬផលិតផលទៅឱ្យអាជីវកម្មនានា។

## ករណីសិក្សា

### រ៉ាមែនដឹកអ្នកដំណើរឆ្លងទីក្រុង

អ្នកដំណើរម្នាក់របស់រ៉ាមែនក្នុងទីក្រុងភ្នំពេញបានផ្តល់ការវាយតម្លៃអំពីកម្រិតវិជ្ជាជីវៈរបស់គាត់សម្រាប់ការធ្វើដំណើរចម្ងាយជិតក្នុងទីក្រុង។ រ៉ាមែនបានសម្រេចចិត្តរៀបចំទំព័រ Facebook ដើម្បីផ្សព្វផ្សាយអំពីការធ្វើដំណើរឆ្លងទីក្រុង។ ដោយមើលឃើញភាពជោគជ័យក្នុងនាមជាអ្នកបើកបរដែលផ្តល់សុវត្ថិភាព និងអាចជឿទុកចិត្តបាន ឥឡូវនេះ រ៉ាមែនកំពុងផ្តល់សេវាកម្មធ្វើដំណើរសម្រាប់មនុស្សជាក្រុមតូចៗរវាងទីក្រុងភ្នំពេញ និងទីក្រុងសៀមរាប។

នៅពេលរ៉ាមែនបញ្ចប់ការធ្វើដំណើរដែលបានកក់តាមរយៈ Facebook គាត់ទទួលបានថ្លៃឈ្នួល ១០០% ដោយសារការកក់មិនបានធ្វើឡើងតាមរយៈកម្មវិធីកក់ការធ្វើដំណើរនោះទេ។ សម្រាប់ការធ្វើដំណើរទៅមក គាត់អាចទទួលបានចន្លោះពី $១៥០ ទៅ $២០០។ ស្តង់ដារវិជ្ជាជីវៈដែលតម្រូវដោយកម្មវិធីកក់ការធ្វើដំណើរពិតជាបានបង្កើនក្តីរំពឹងចំពោះចំណូលសុទ្ធនាពេលអនាគតរបស់រ៉ាមែនទាំងនៅក្នុងនិង ក្រៅកម្មវិធី។

# សម្របខ្លួនទៅនឹងពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក អំឡុងពេលឆ្លងរាលដាលនេះ

**ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩បានបណ្តាលឱ្យមានការយកចិត្តទុកដាក់ជាសំខាន់ទៅលើហានិភ័យនៃការប៉ះពាល់រាងកាយប្រចាំថ្ងៃ។**

ក្នុងអំឡុងការឆ្លងរាលដាលនេះ ការសម្របខ្លួនទៅនឹងវិធីសាស្រ្តធម្មតាសម្រាប់ធ្វើដំណើរ និងដឹកជញ្ជូនគឺជារឿងសំខាន់ដែលរួមមាន៖



## អនាម័យផ្ទាល់ខ្លួន

មុខងារនេះជួយអ្នកក្នុងការគ្រប់គ្រងភាពទំនេររបស់អ្នកនៅលើកម្មវិធីនេះ។ ប្រសិនបើអ្នកកំពុងរង់ចាំទទួលការងារ អ្នកគ្រាន់តែរក្សាស្ថានភាពមានអ៊ីនធឺណិត និងនៅទំនេរជាការស្រេច។

## អនាម័យរថយន្ត

ធ្វើអនាម័យលើយានជំនិះរបស់អ្នកដោយប្រើផលិតផលកម្ចាត់បាក់តេរី នៅចន្លោះពេលដឹកអតិថិជនម្នាក់ៗ។ ផ្តល់ម៉ាស់ដល់អតិថិជនណាដែលគ្មានម៉ាស់។

## ការដឹកជញ្ជូនដោយមិនបាច់ប៉ះ

សម្រាប់ការងារដឹកជញ្ជូន សូមសាកសួរប្រព័ន្ធរបស់អ្នកថាតើពួកគេផ្តល់ការដឹកជញ្ជូន 'ដោយមិនបាច់ប៉ះ' ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងវីរុសឬអត់។ ជាទូទៅ ចំណុចនេះពាក់ព័ន្ធនឹងការធានាថា អតិថិជនទទួលបានទំនិញតាមការកុម្ម៉ង់ ប៉ុន្តែមិនហុចឱ្យដោយផ្ទាល់ដៃឡើយ។

## មិនប្រើសាច់ប្រាក់

មូលហេតុមួយទៀតក្នុងការប្តូរទៅជាការទូទាត់ប្រាក់តាមអនឡាញគឺ ដោយសារតែការកាន់សាច់ប្រាក់អាចបង្កើនហានិភ័យនៃការឆ្លងវីរុស។ ប្រព័ន្ធរបស់អ្នកគួរតែផ្តល់ដំណោះស្រាយទូទាត់ប្រាក់ដោយមិនប្រើសាច់ប្រាក់។

## បង្ហាញថាអ្នកយកចិត្តទុកដាក់

ជម្រាបអតិថិជនអំពីវិធានការសុខភាព និងសុវត្ថិភាពរបស់អ្នក។ ប្រសិនបើអ្នកមានទំព័រផ្សព្វផ្សាយសង្គម សូមជម្រាបអ្នកចូលមើល និងអតិថិជនអំពីរបៀបដែលអ្នកកំពុងប្រតិកម្មនឹងការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

## ករណីសិក្សា

### ស្រីកាចាប់ផ្តើមការដឹកជញ្ជូន 'ដោយមិនបាច់ប៉ះ'

ស្រីកាដឹងច្បាស់ថាអតិថិជនមានការព្រួយបារម្ភអំពីការប៉ះពាល់រាងកាយ និងហានិភ័យនៃការឆ្លងវីរុសនេះ។ គាត់មានកេរ្តិ៍ឈ្មោះល្អថា មានស្តង់ដារវិជ្ជាជីវៈស្រាប់ហើយ ប៉ុន្តែឥឡូវនេះបានឈានទៀងមួយជំហានទៀតតាមរយៈការផ្តល់ការដឹកជញ្ជូន 'ដោយមិនបាច់ប៉ះ'។

របៀបរបបដឹកជញ្ជូនថ្មីពាក់ព័ន្ធនឹងការដឹកជញ្ជូនគ្រឿងទេសរបស់ស្រីកាទៅដល់ទ្វារមុខនៃអាសយដ្ឋានដឹកជញ្ជូន បន្ទាប់មកចេញមកវិញ រួចហៅទូរសព្ទទៅអតិថិជននោះ។ គាត់ក៏ផ្តល់កូនសៀវភៅណែនាំអំពីរបៀបលាងគ្រឿងទេសមុននឹងចម្អិន ឬទទួលទានផងដែរ។ ដោយយកស្រីកាជាគំរូ ឥឡូវនេះ ប្រព័ន្ធដឹកជញ្ជូនបានតម្រូវឱ្យអ្នកបើកបរទាំងអស់ធ្វើបែបនេះដែរ។

# ការអនុលោមតាមច្បាប់

ការធ្វើជាអ្នកដឹកជញ្ជូន ឬអ្នកបើកបរសម្រាប់អ្នកដំណើរឱ្យប្រព័ន្ធអនទ្បាញនឹងតម្រូវឱ្យអនុលោមតាមច្បាប់ក្រមព្រហ្មទណ្ឌ និងច្បាប់ក្រមរដ្ឋប្បវេណីធម្មតាទាំងអស់ដូចជាការគោរពច្បាប់ចរាចរណ៍ ការចុះកិច្ចសន្យាពាណិជ្ជកម្ម (រួមទាំងការដោះស្រាយវិវាទ) និងទំនួលខុសត្រូវចំពោះការធ្វេសប្រហែសផងដែរ។ ច្បាប់ថ្មីរបស់កម្ពុជាស្តីពីការការពារអតិថិជនក៏នឹងត្រូវអនុវត្តផងដែរ។ នេះមានន័យថា អ្នកត្រូវតែផ្តល់ព័ត៌មានឱ្យអតិថិជនឱ្យបានត្រឹមត្រូវ រួមទាំងអ្វីផ្សេងៗដូចជា អត្តសញ្ញាណក្រុមហ៊ុន លក្ខខណ្ឌទូទាត់ប្រាក់ ការលុបចោល និងការបង្វិលសងផងដែរ។ ប្រព័ន្ធដឹកជញ្ជូនតាមអនទ្បាញនឹងអាចផ្តល់ដំបូន្មានអំពីចំណុចនេះដល់អ្នក។

ច្បាប់ជាក់លាក់មួយចំនួនសម្រាប់ក្រុមហ៊ុនលក់តាមអនទ្បាញនានាក៏មានផងដែរ។ ការចុះឈ្មោះសម្រាប់អ្នកចូលរួមធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេទ្បិចត្រូនិកនឹងតម្រូវឱ្យមានស្របតាមច្បាប់ថ្មីរបស់កម្ពុជាស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេទ្បិចត្រូនិក ហើយច្បាប់ធម្មតាទាំងអស់ស្តីពីពន្ធអាជីវកម្មនឹងត្រូវអនុវត្តចំពោះអាជីវកម្មលក់តាមអនទ្បាញ។ ច្បាប់ថ្មីនេះក៏តម្រូវឱ្យអ្នកការពារទិន្នន័យ និងព័ត៌មានដែលអ្នកទទួលបានអំពីអតិថិជនផងដែរ។ ប្រសិនបើអ្នកចូលរួមជាមួយប្រព័ន្ធដឹកជញ្ជូន សូមសាកសួរថា តើពួកគេអាចជួយអ្នកក្នុងការការពារទិន្នន័យនេះ និងអនុលោមតាមច្បាប់នេះដោយរបៀបណា។

មានបញ្ហាផ្លូវច្បាប់មួយចំនួនដែលមានភាពជាក់លាក់ចំពោះអ្នកបើកបរសម្រាប់ការធ្វើដំណើរ ឬការដឹកជញ្ជូនដែលកំពុងរីកវិវឌ្ឍ នៅក្នុងប្រទេសនានាជុំវិញពិភពលោក។ ឧទាហរណ៍ កម្មវិធីដឹកជញ្ជូនឬធ្វើដំណើរភាគច្រើននឹងមិនចាត់ទុកអ្នកជា 'បុគ្គលិក' នោះទេ ហើយក៏មិនទូទាត់ប្រាក់ការងារដូចធម្មតាដែរ។ ទន្ទឹមនឹងនេះ តើកម្មវិធីដឹកជញ្ជូន ឬធ្វើដំណើរមានទំនួលខុសត្រូវដូចម្តេចខ្លះក្នុងករណីមានគ្រោះថ្នាក់? តើពួកគេអាចទទួលខុសត្រូវមួយផ្នែកទេ ប្រសិនបើអ្នកមានរបួសក្នុងអំឡុងពេលធ្វើការ?បញ្ហាផ្លូវច្បាប់ទាំងនេះកំពុងមានការពិភាក្សាដេញដោលយ៉ាងក្តៅគគុកនៅជុំវិញពិភពលោក ហើយនឹងផ្លាស់ប្តូរបន្តិចម្តងៗ។

# ការទទួលការបង់ប្រាក់

ប្រសិនបើអ្នកចូលរួមជាមួយប្រព័ន្ធដឹកជញ្ជូន ឬធ្វើដំណើរ ពួកគេទំនងជានឹងផ្តល់គ្រឿងសម្រួលសម្រាប់ទទួលការបង់ប្រាក់តាមអនទ្បាញ។ ជាធម្មតា គ្រឿងសម្រួលនេះជាកន្លែងដែលអតិថិជនរបស់អ្នកទូទាត់ប្រាក់តាមរយៈកម្មវិធីដោយប្រើបណ្ណឥណពន្ធ/បណ្ណឥណទាន ហើយប្រព័ន្ធដឹកជញ្ជូនប្រមូលប្រាក់ រួចផ្ញើចំនួនទឹកប្រាក់ដែលពួកគេជំពាក់ទៅគណនីធនាគាររបស់អ្នកដោយផ្ទាល់។

សម្រាប់ការដឹកអ្នកដំណើរ ការបញ្ជាក់ការកក់តាមរយៈកម្មវិធីគួរតែបញ្ជាក់ថា តើអតិថិជនចង់បង់ប្រាក់តាមអនទ្បាញ ឬបង់ជាសាច់ប្រាក់។ ក្រុមហ៊ុនធំៗ និងរដ្ឋាភិបាលបានប៉ុនប៉ងប្តូរទៅធ្វើប្រតិបត្តិការទាំងនេះតាមអនទ្បាញវិញ។ ការទូទាត់ប្រាក់តាមអនទ្បាញក៏នឹងអាចបញ្ចៀសហានិភ័យនៃការឆ្លងវីរុសកូវីដ-១៩ តាមរយៈការកាន់ក្រដាសប្រាក់ និងកាក់បានផងដែរ។

ប្រសិនបើអ្នកសម្រេចចិត្តធ្វើអាជីវកម្មតាមអនទ្បាញដោយខ្លួនអ្នកផ្ទាល់ អ្នកគួរតែពិភាក្សាជាមួយធនាគាររបស់អ្នកអំពីប្រភេទនៃគ្រឿងសម្រួលសម្រាប់អាជីវករដែលពួកគេផ្តល់ជូនជាមុនសិន។ ចំណុចនេះអាចពាក់ព័ន្ធនឹងការរៀបចំ 'គណនីអាជីវករ' (ដើម្បីទទួលការទូទាត់ប្រាក់ក្នុងនាមជាអាជីវកម្ម) និង 'ច្រកទូទាត់ប្រាក់' (ដែលភ្ជាប់ហាងរបស់អ្នកជាមួយគណនីអាជីវករ)។

# ការលក់ សេវាកម្មដឹកជញ្ជូន និងធ្វើដំណើរ តាមអនឡាញ នៅប្រទេសកម្ពុជា

GOOD PRACTICE GUIDE CAMBODIA

ក្រុមហ៊ុនខាងក្រោមនេះបានចូលរួមចំណែកក្នុងការបង្កើតគោលការណ៍ណែនាំសម្រាប់ការអនុវត្តល្អ (Good Practice Guidelines, GPG) នេះ ហើយអាចទាក់ទងដើម្បីទទួលបានព័ត៌មានបន្ថែមស្តីពីការលក់ទំនិញ និងសេវាកម្មតាមអ៊ីនធឺណិត។

សមាគមសហគ្រិនស្ត្រីកម្ពុជា CAMBODIA WOMEN ENTREPRENEURS ASSOCIATION

camboticket

woomentum Cambodia

grocerdel Grocery Delivery

BOOKMEBUS where every corner is bookable

MEALTEMPLE

ipay88

TADA Powered by MVL

EUROCHAM CAMBODIA

auscham australian chamber of commerce in cambodia

delishop ONLINE SUPERMARKET Phnom Penh

SHOPRUNBACK


**ការប្រកាសមិនទទួលខុសត្រូវ**

ការបោះពុម្ពផ្សាយនេះត្រូវបានផ្តល់មូលនិធិដោយ
**រដ្ឋាភិបាលអូស្ត្រាលី** តាមរយៈ **ក្រសួងការបរទេស និងពាណិជ្ជកម្ម។**

ទស្សនៈដែលបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ តែម្នាក់ប៉ុណ្ណោះហើយមិនមែនជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីទេ។